ឯកសារសិក្សាគោលនយោបាយសង្ខេប

ការចេញផ្សាយលេខ ០១ ឆ្នាំ២០១៩

ការបោះពុម្ពផ្សាយរបស់
ក្រុមប្រឹក្សាស្រាវជ្រាវអប់រំ

ក + ខ - គ × ឧ ÷ Л ∑ ψ ∫ ф Ω ៛ $ ☺

*ការបោះផ្សាយនេះឧបត្ថម្ភដោយគម្រោងហិរញ្ញវត្ថុធនាគារអភិវឌ្ឍន៍អាស៊ី No.3427-CAM (COL)*

# តើ PISA-D ប្រាប់យើងអ្វីខ្លះអំពីការអប់រំនៅក្នុងប្រទេសកម្ពុជា?

ហេង គ្រេង, អ៊ុង ជិនណា, សរ សារិន, ជួង ចន្ថា និង តុល បញ្ញា

ទំនាក់ទំនងអ្នកនិពន្ធ | ហេង គ្រេង នាយកដ្ឋានធានាគុណភាពអប់រំ | អ៊ីម៉ែល៖ krengheng@gmail.com

## ខ្លឹមសារសំខាន់ៗ៖

- ការវាយតម្លៃការសិក្សារបស់សិស្សកម្រិតប្រព័ន្ធ ដូចជា PISA-D ផ្តល់ភស្តុតាង និងទិន្នន័យ ដែលបង្ហាញពីការសិក្សារបស់សិស្ស ក៏ដូចជាប្រព័ន្ធអប់រំទាំងមូលនៅក្នុងប្រទេសកម្ពុជា។ ជាងនេះទៅទៀត វាក៏បានបង្ហាញការអប់រំរបស់ប្រទេសកម្ពុជាទៅដល់ពិភពលោក។ យ៉ាងណាមិញ ភស្តុតាង និងទិន្នន័យត្រូវតែបកស្រាយឱ្យទៅជាគោលនយោបាយ និងការអនុវត្តផ្សេងៗ។
- កម្ពុជាត្រូវដោះស្រាយបញ្ហាប្រឈមសំខាន់មួយចំនួនទាក់ទងនឹងសមិទ្ធផលសិក្សា និងលទ្ធផលសិក្សាទាបរបស់សិស្ស និងកសាងមូលដ្ឋានគ្រឹះនៃភាពជោគជ័យនៅកម្រិតសាលារៀន។
- សិស្សប្រហែល ១០% នៃសិស្សក្នុងប្រទេសកម្ពុជាដែលមានអាយុ១៥ឆ្នាំ អាចហៅបានថា “ជាសិស្ស SDG“ លើផ្នែកអំណាន និងគណិតវិទ្យា៖ ពួកគេមានកម្រិតសមត្ថភាពអប្បបរិមា (កម្រិតទី២) លើតេស្តវាយតម្លៃ PISA-D និងអាចធ្វើការប្រៀបធៀបបានជាមួយសិស្សមួយចំនួននៅក្នុងបណ្តាប្រទេសដែលជាសមាជិក OECD។ បទពិសោធន៍ពីពួកគេ និងប្រព័ន្ធសាលារៀនរបស់ពួកគេ អាចត្រួសត្រាយឱ្យមានការអនុវត្តការគ្រប់គ្រងតាមសាលារៀនប្រកបដោយប្រសិទ្ធភាព និងបង្កើតជាម៉ូដែលមួយសម្រាប់កែលម្អលទ្ធផលសិក្សារបស់សិស្ស។
- ការចូលរួមក្នុងកម្មវិធី PISA-D និង PISA ២០២១ របស់កម្ពុជា មានន័យថាកម្មវិធីសិក្សា ការបង្រៀន និងការវាយតម្លៃត្រូវតែមានភាពស្របគ្នា និងឈានទៅរកការអប់រំដោយផ្អែកលើសមត្ថភាព (អ្វីដែលសិស្សចេះ និងអាចប្រើចំណេះទាំងនោះក្នុងការរស់នៅ និងការប្រកបការងារក្នុងសង្គមបែបទំនើប) ដើម្បីរៀបចំសិស្សសម្រាប់អនុវត្តកិច្ចការរៀនសូត្រតាមទម្រង់របស់ PISA។

## សេចក្តីផ្តើម

ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស មិនថានៅកម្រិតថ្នាក់រៀន ឬកម្រិតប្រព័ន្ធនោះទេ គឺជាធាតុគន្លឹះដ៏សំខាន់មួយក្នុងចំណោមធាតុគន្លឹះសំខាន់ផ្សេងទៀតនៅក្នុងប្រព័ន្ធអប់រំ។ វាមិនត្រឹមតែវាស់វែងអំពីសមិទ្ធផលសិក្សារបស់សិស្សតាមចំណុចដៅណាមួយនោះទេ ប៉ុន្តែវាក៏ដើរតួជាប៉ារ៉ាម៉ែត្រសម្រាប់ពិនិត្យមើលលើកម្មវិធីសិក្សា និងសម្រាប់ធ្វើការវាយតម្លៃការបង្រៀន និងរៀនផងដែរ (UNESCO, 2015) ។ និយាយឱ្យចំ ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតប្រព័ន្ធ មានតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ជាព័ត៌មានផ្សេងៗអំពីអ្វីដែលដែលអាចធ្វើបាន និងអ្វីដែលត្រូវតែធ្វើដោយខានតែបាននៅក្នុងដំណើរការកំណែទម្រង់អប់រំ។ វត្តមាននៃការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតប្រព័ន្ធ ជាការបង្ហាញពីការធានាថា ផែនការយុទ្ធសាស្ត្រ និងសកម្មភាពផ្សេងៗនៅកម្រិតគោលនយោបាយ និងកម្រិតសាលារៀនមានភាពពាក់ព័ន្ធគ្នា ព្រមទាំងឆ្ពោះទៅរកការបង្កើនគុណភាពអប់រំ និងការអប់រំប្រកបដោយចីរភាព។

ដើម្បីត្រួតត្រាយគោលនយោបាយ និងការអនុវត្តផ្សេងៗក្នុងវិស័យអប់រំ កម្ពុជាបានខិតខំអភិវឌ្ឍប្រព័ន្ធវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតប្រព័ន្ធ មានតាំងពីការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិ ថ្នាក់ទី៣ ទី៦ ទី៨ និងទី១១ រហូតដល់តេស្តវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់តំបន់ តេស្តវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សបឋមសិក្សានៅតំបន់អាស៊ីអាគ្នេយ៍ (SEA-PLM) និងក្នុងពេលថ្មីនេះ បានចូលរួមការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតអន្តរជាតិ ដែលមានឈ្មោះថាកម្មវិធីអន្តរជាតិស្តីពីវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ PISA-D (MoEYS, 2018)។ បើទោះជាបញ្ញត្តិនៃការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតប្រព័ន្ធហាក់ដូចជាថ្មីនៅក្នុងប្រទេសកម្ពុជា ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតប្រព័ន្ធនេះកំពុងតែមានភាពចាំបាច់ខ្លាំងក្នុងកំណែទម្រង់អប់រំសព្វថ្ងៃនេះ ខណៈដែលនវានុវត្តន៍ និងការកែលម្អកម្មវិធីសិក្សា ការបង្រៀន និងរៀន និង ជាពិសេស ការគ្រប់គ្រងតាមសាលារៀន ត្រូវការភស្តុតាង និងទិន្នន័យដើម្បីបញ្ជាក់។ ប្រសិនបើធ្វើការបកស្រាយ និងប្រើប្រាស់បានត្រឹមត្រូវ នោះភស្តុតាង និងទិន្នន័យដែលបានមកពីការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតប្រព័ន្ធអាចតម្រែតម្រង់ការអនុវត្តដ៏ល្អ ទាំងនៅកម្រិតគោលនយោបាយ និងកម្រិតអនុវត្ត។

សេចក្តីសង្ខេបនេះពិភាក្សាអំពីតួនាទីរបស់ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតប្រព័ន្ធក្នុងការផ្តល់ជាភស្តុតាងផ្សេងៗអំពីគោលនយោបាយ និងការអនុវត្តផ្សេងៗក្នុងការអប់រំរបស់ប្រទេសកម្ពុជាធៀបទៅនឹងកំណែទម្រង់នាពេលបច្ចុប្បន្ន និងរំលេចចេញនូវគោលនយោបាយ និងសកម្មភាពផ្សេងៗដែលជះឥទ្ធិពលដល់ការសិក្សារបស់សិស្សដោយផ្ទាល់ តាមរយៈការដាក់បញ្ចូលគ្នានូវភស្តុតាងដែលបានមកពីបទពិសោធន៍របស់កម្ពុជាក្នុងការចូលរួមជាមួយកម្មវិធីវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតអន្តរជាតិ ដែលត្រូវគេស្គាល់ជាសកលថា PISA-D (MoEYS, 2018)។ ឯកសារនេះក៏បានវិភាគទៅលើស្ថានភាពការអប់រំនាពេលបច្ចុប្បន្ន ក្នុងបរិបទ PISA 2021 ដោយពិភាក្សាសំខាន់ លើសំណួរដូចជា តើ PISA 2021 មានន័យអ្វីខ្លះចំពោះកម្ពុជា? តើយើងទៅដល់ណា ពីស្ថានភាពអប់រំនាពេលបច្ចុប្បន្ន?

## កម្ពុជាក្នុងបរិបទ PISA-D និងអប់រំសកល

កម្ពុជាបានចូលរួមក្នុងកម្មវិធី PISA-D នៅក្នុងឆ្នាំ២០១៦ ជាមួយនឹងប្រទេសចំនួន៨ផ្សេងទៀតជាសមាជិក (អេក្វាទ័រ ប៊ូតង់ ក្វាតេម៉ាឡា សំប៊ី សេណេហ្គាល់ ប៉ារាហ្គាយ ហុងឌុយរ៉ាស និងប៉ាណាម៉ា)។ PISA-D ជាកម្មវិធីថ្មីសម្រាប់ប្រទេសដែលមានប្រាក់ចំណូលទាប និងមធ្យម និង ភាគច្រើន យកលំនាំតាមទម្រង់របស់តេស្ត PISA ដែលជាការស្ទង់មតិកម្រិតអន្តរជាតិ ធ្វើឡើងក្នុងរយៈពេល៣ឆ្នាំម្តង និងមានគោលបំណងចម្បង ដើម្បីវាយតម្លៃប្រព័ន្ធអប់រំទូទាំងសកលលោក ដោយធ្វើតេស្តទៅលើចំណេះដឹង និងបំណិនរបស់សិស្សអាយុ១៥ឆ្នាំ ដែលកំពុងសិក្សានៅកម្រិតថ្នាក់ពីទី៧ឡើងទៅ។ PISA-D វាយតម្លៃទៅលើកម្រិតដែលសិស្សអាយុ១៥ឆ្នាំ (ជិតចប់ការអប់រំកម្រិតមូលដ្ឋាន) ទទួលបានចំណេះដឹង និងបំណិនសំខាន់ៗ សម្រាប់ការចូលរួមពេញលេញទាំងការងារ និងការរស់នៅក្នុងសង្គមទំនើប។ ការវាយតម្លៃផ្តោតលើមុខវិជ្ជាស្នូលក្នុងសាលារៀនដូចជា វិទ្យាសាស្ត្រ អំណាន និងគណិតវិទ្យា និងមិនគ្រាន់តែសង្កត់ធ្ងន់លើថាតើសិស្សអាចបង្កើតឡើងវិញនូវចំណេះដឹងដែលមានក្នុងសាលារៀន ប៉ុន្តែក៏បានធ្វើការវាស់វែងថាតើសិស្សអាចទាញយកពីអ្វីដែលពួកគេបានសិក្សា និងអាចយកចំណេះដឹងទាំងនោះទៅអនុវត្តក្នុងបរិបទដែលមិនធ្លាប់ស្គាល់ ទាំងក្នុង និងក្រៅសាលារៀន។ គោលវិធីនេះឆ្លុះបញ្ចាំងពីការពិតអំពីប្រទេសដែលមានសេដ្ឋកិច្ចទំនើបផ្តល់រង្វាន់ដល់អ្នកណាម្នាក់ ដោយមិនផ្តោតទៅលើអ្វីដែលពួកដឹង ប៉ុន្តែផ្តោតទៅលើអ្វីដែលពួកគេអាចធ្វើបានជាមួយអ្វីដែលពួកគេដឹង។

PISA-D វាយតម្លៃសិស្សកម្ពុជាចំនួន៥១៦២នាក់ ជាតំណាងឱ្យសិស្សអាយុ១៥ឆ្នាំទូទាំងប្រទេសដែលកំពុងសិក្សាចាប់ពីថ្នាក់ទី៧ឡើងទៅ។ សិស្សទាំងនេះតម្រូវឱ្យអង្គុយធ្វើតេស្តរយៈពេល២ម៉ោង និងបំពេញកម្រងសំណួរអំពីបរិបទជុំវិញ ដើម្បីវាស់វែងពីកត្តាផ្សេងៗដែលមានឥទ្ធិពលទៅលើការសិក្សារបស់ពួកគេ ដូចជា សាលារៀន ថ្នាក់រៀន ផ្ទះ និងបរិយាកាសសហគមន៍ជាដើម។ ការចូលរួមក្នុងកម្មវិធី PISA-D មានន័យថា ការអប់រំរបស់ប្រទេសកម្ពុជា មិនត្រឹមតែមានទំនាក់ទំនងនឹងបរិបទប្រទេសរបស់ខ្លួនប៉ុណ្ណោះទេ តែក៏មានទាក់ទងនឹងនិន្នាការអប់រំសកលផងដែរ ជាពិសេស ទាក់ទងទៅនឹងគោលដៅអប់រំសកលដូចដែលបានចង្អុលបង្ហាញនៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG) ខណៈដែលកម្រិតសមត្ថភាពមូលដ្ឋានជាសកល គឺជាអ្វីដែលប្រទេសនីមួយៗចង់បាន (MoEYS, 2018) ។ ទន្ទឹមគ្នានេះដែរ ការចូលរួមនេះក៏ជាការឱកាសមួយដើម្បីឱ្យកម្ពុជារៀបចំខ្លួនឱ្យបានប្រសើរឡើងសម្រាប់កម្មវិធី PISA ២០២១។ ដូចនេះ លទ្ធផលពី PISA-D បានសារៈសំខាន់ណាស់សម្រាប់កំណែទម្រង់អប់រំនៅកម្ពុជា និងលទ្ធផលសិក្សារបស់សិស្សសម្រាប់វដ្ត PISA បន្ទាប់ទៀតនេះ។ បើទោះជាដូច្នេះក៏ដោយ តែការអប់រំនៅកម្ពុជាត្រូវដោះស្រាយបញ្ហាប្រឈមធំចំនួនពីរធំៗគឺ ទីមួយ ត្រូវធ្វើយ៉ាងណាឱ្យឆ្លើយតបទៅនឹងតម្រូវការក្នុងស្រុក និងមួយវិញទៀត ត្រូវបន្សុីខ្លួនឯងទៅហ្នឹងបរិបទនៃការអប់រំសកល។ ចំណុចនេះត្រូវការឱ្យមាននវានុវត្តន៍នៃការបង្រៀន និងរៀនដែលជំរុញនូវ “របៀបបង្រៀន និងរៀន” ជាជាងការផ្តោតតែលើ “អ្វីដែលត្រូវបង្រៀន និងរៀន”។ ភស្តុតាង និងទិន្នន័យពីការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតប្រព័ន្ធពិតជាត្រូវការជាចាំបាច់សម្រាប់ប្រទេសកម្ពុជា។

## តើ PISA-D ប្រាប់យើងអ្វីខ្លះអំពីការអប់រំនៅក្នុងប្រទេសកម្ពុជា?

### *សមិទ្ធផលសិក្សាសម្រេចបាន និងលទ្ធផលសិក្សា*

លទ្ធផល PISA-D បង្ហាញថា ប្រទេសកម្ពុជាប្រឈមបញ្ហាចំនួនពីរក្នុងពេលដំណាលគ្នា នៅក្នុងប្រព័ន្ធអប់រំរបស់ខ្លួនគឺ សិស្សអាយុ១៥ឆ្នាំមិនត្រឹមតែសម្រេចបាននូវការអប់រំទាបប៉ុណ្ណោះទេ ថែមទាំងលទ្ធផលសិក្សាមិនល្អផងដែរ។ ចំពោះលទ្ធផល

សិក្សាសម្រេចបានរបស់សិស្ស ប្រទេសកម្ពុជាត្រូវការរយៈពេលវែងដើម្បីបន្ថយគម្លាតអត្រាចូលរៀននៅកម្រិតមធ្យមសិក្សា បើធៀបនឹងប្រទេសដែលជាសមាជិក PISA-D ASEAN និង OECD ។ សិស្សអាយុ១៥ឆ្នាំ ដែលកំពុងសិក្សាពីថ្នាក់ទី៧ដល់១២នៅក្នុងប្រទេសកម្ពុជា មានតែចំនួន ២៨.១% នៃសិស្សអាយុ១៥ទាំងអស់នៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះ ដែលមានន័យថា សិស្សដែលមានអាយុ១៥ឆ្នាំ ប្រហែលជា៧២% បានបោះបង់ការសិក្សា ឬមានការយឺតយ៉ាវក្នុងការចូលរៀន ជាពិសេស សិស្សប្រុស។ សមិទ្ធផលសិក្សាសម្រេចបានរបស់សិស្សអាយុ១៥ឆ្នាំនៅក្នុងប្រទេសកម្ពុជាអាចប្រៀបធៀបបានជាមួយប្រទេសសេណេហ្គាល់ និងសំប៊ីដែលយុវជនភាគច្រើនស្ថិតនៅក្រៅសាលារៀន ប៉ុន្តែទាបជាងខ្លាំងបើធៀបនឹងប្រទេស អេក្វាទ័រ (៦១%) ប៉ារ៉ាហ្គាយ (៥៦%) ក្វាតេម៉ាឡា (៤៧%) និងហុងឌុយរ៉ាស (៤១%)។ សមិទ្ធផលសិក្សាសម្រេចបានកម្រិតទាបបែបនេះ ធ្វើឱ្យឱកាសការងាររបស់សិស្សថយចុះ និងជាបញ្ហាប្រឈមមួយក្នុងការខិតខំបង្កើនកម្លាំងពលកម្ម ដើម្បីគាំទ្រដល់ទម្រង់សេដ្ឋកិច្ចដែលប្រទេសកម្ពុជាចង់បានឱ្យក្លាយទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០ ខាងមុខនេះ។ សមិទ្ធផលសិក្សាទាបរបស់សិស្សអាយុ១៥ឆ្នាំ ក៏មានន័យថា កម្ពុជាត្រូវរៀបចំវិធានការដែលមានប្រសិទ្ធភាពបន្ថែមទៀត ដើម្បីធានាឱ្យសិស្សមានឱកាសបញ្ចប់យ៉ាងហោចណាស់ត្រឹមកម្រិតមធ្យមសិក្សាបឋមភូមិ (ការអប់រំកម្រិតមូលដ្ឋាន ៩ឆ្នាំ)។

សមិទ្ធផលសិក្សាសម្រេចបានទាបនៅកម្រិតមធ្យមសិក្សានេះបង្ហាញថា សិស្សចូលរៀនយឺត រៀនត្រួតថ្នាក់ ឬបោះបង់ការសិក្សាចាប់តាំងពីកម្រិតបឋមសិក្សាមកម្លេះ។ នៅក្នុងប្រព័ន្ធអប់រំនៃប្រទេសដែលមានសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ សិស្សដែលមានសមត្ថភាពទាបប្រហែលជាមិនអាចឆ្លងភូមិសិក្សាដូចសិស្សដ៏ទៃបានទេ។ សិស្សដែលអាចបន្តការសិក្សាបាន ជាទូទៅពួកគេជាសិស្សដែលមានការតស៊ូ ឬមានប្រវត្តិនៃការសិក្សាខ្លាំង។ ការគិតបែបនេះគឺផ្អែកលើភស្តុតាងក្នុងករណីប្រទេសវៀតណាម ខណៈអត្រាសិស្សអាយុ១៥ឆ្នាំដែលបានចូលរួមក្នុងកម្មវិធី PISA គឺមានប្រហែលជា ៤៨% ប៉ុណ្ណោះ តិចជាងច្រើនបើធៀបនឹងមធ្យមភាគរបស់ OECD (៨៩%) ប៉ុន្តែប្រទេសវៀតណាមទទួលបានលទ្ធផលល្អជាងបណ្តាប្រទេសដែលសមាជិក OECD ជាច្រើនលើផ្នែកវិទ្យាសាស្ត្រ នៅក្នុងកម្មវិធី PISA ២០១២ និង២០១៥។ អ្នកបង្កើតគោលនយោបាយជាច្រើនគេរិនរំលឹកថា លទ្ធផលល្អរបស់ប្រទេសវៀតណាមអាចបង្ហាញពីភាពជោគជ័យមួយក្នុងប្រព័ន្ធអប់រំ ប៉ុន្តែទាមទារឱ្យមានការវិភាគបន្ថែមដើម្បីផ្ទុះបញ្ជាំងការពិតនៃប្រព័ន្ធអប់រំទាំងមូល ក្នុងហេតុផលថា ប្រព័ន្ធនោះប្រហែលជារក្សាបានតែសិស្សពូកែប៉ុណ្ណោះ ខណៈដែលទុកសិស្សផ្សេងទៀតឱ្យបោះបង់ការសិក្សា។ តែយ៉ាងណាក៏ដោយ ក្នុងស្ថានភាព ស្រដៀងគ្នានៃសមិទ្ធផលសិក្សាសម្រេចបាន ប្រទេសកម្ពុជាមិនសម្រេចបានដូចទៅនឹងភាពជោគជ័យរបស់ប្រទេសវៀតណាមទេ ហើយត្រូវដោះស្រាយបញ្ហាប្រឈមធំពីរ គឺសមិទ្ធផលសិក្សាសម្រេចបានទាប និងលទ្ធផលសិក្សាទាបផងដែរ។

*រូបភាពទី 1៖ សមិទ្ធផលសិក្សាសម្រេចបានរបស់សិស្សអាយុ១៥ឆ្នាំ ចាប់ពីថ្នាក់ទី៧ឡើងទៅ*




ប្រភព៖ ទិន្នន័យ PISA 2015 និង PISA-D

លទ្ធផល PISA-D បង្ហាញថា កម្ពុជាមានអ្វីៗជាច្រើនដែលត្រូវធ្វើបន្តទៀតដើម្បីធ្វើឱ្យពិន្ទុ PISA បានល្អ បើទោះជាសិស្សអាយុ១៥ឆ្នាំនៅក្នុងប្រទេសកម្ពុជាទទួលបានលទ្ធផលល្អជាងសិស្សអាយុដូចគ្នានៅក្នុងប្រទេសសេណេហ្គាល់ និងសំប៊ី លើគ្រប់មុខវិជ្ជាក៏ដោយ។ អ្វីដែលយើងអាចមើលឃើញនោះគឺ លើផ្នែកអំណាន និងវិទ្យាសាស្ត្រ សិស្សកម្ពុជាអាយុ១៥ឆ្នាំជាមធ្យមទទួលបានលទ្ធផលសិក្សាទាបនៅឡើយ បើធៀបនឹងសិស្សនៅក្នុងប្រទេសដែលជាសមាជិក PISA-D និង ASEAN ផ្សេងទៀត(វៀតណាម ថៃ ឥណ្ឌូនេស៊ី និងសាំងហ្គាពួរ)។ សាលារៀនតាមជនបទ ប្រជុំជន និងសាលារៀនដែលមានធនធានខ្វះខាតនៅក្នុងប្រទេសកម្ពុជាទទួលបានលទ្ធផលសិក្សាកាន់តែទាប។ ទិដ្ឋភាពរួមមួយដែលគួរកត់សម្គាល់ពី PISA-D គឺថា សាលារៀនឯកជនទទួលបានលទ្ធផលសិក្សារបស់សិស្សខ្ពស់ជាងសាលារៀនរដ្ឋ រហូតដល់ទៅប្រហែល២ឆ្នាំសិក្សា។ ភាពខុសគ្នានៃលទ្ធផលសិក្សានេះ បង្ហាញអំពីវិសមភាពនៃការអប់រំនៅក្នុងប្រព័ន្ធទាំងពីរ។

សិស្សកម្ពុជាទទួលបាន ៣២១ពិន្ទុ លើផ្នែកអំណាន និង៣៣០សម្រាប់ផ្នែកវិទ្យាសាស្ត្រ ខណៈដែលពិន្ទុសរុបខ្ពស់បំផុតប្រហែលជា៧០០ពិន្ទុ។ ជាមធ្យម សិស្សនៅក្នុងបណ្តាប្រទេសសមាជិក PISA-D ទទួលបាន៣៤៦ពិន្ទុ លើផ្នែកអំណាន និង៣៤៩ពិន្ទុ លើផ្នែកវិទ្យាសាស្ត្រ។ មធ្យមភាគសិស្សអាយុ១៥ឆ្នាំតាមបណ្តាប្រទេសនៅក្នុងASEAN ទទួលបាន ៤៣០ពិន្ទុ លើផ្នែកអំណាន និង៤៤៧ពិន្ទុ លើផ្នែកវិទ្យាសាស្ត្រ (OECD, 2013; OECD, 2016); ខណៈដែលមធ្យមភាគសិស្សនៅក្នុងបណ្តាប្រទេសសមាជិក OECD ទទួលបានដល់ទៅប្រហែល ៤៩០ពិន្ទុ លើគ្រប់ផ្នែកទាំងអស់ ដែលសមមូលទៅនឹងកម្រិតទី៣ នៃកម្រិតសមត្ថភាពទាំង៦

របស់ PISA។ ពិន្ទុ ៤១០ ឬខ្ពស់ជាងនេះ បង្ហាញថាសិស្សសម្រេចបានកម្រិតសមត្ថភាពអប្បបរមា ឬកម្រិតមូលដ្ឋាន (កម្រិតទី២) ស្របគ្នាទៅនឹងការរំពឹងទុកនៅក្នុងក្របខណ្ឌ SDG4។

កម្រិតសមត្ថភាពទី២ គឺជាកម្រិតលទ្ធផលសិក្សាមូលដ្ឋានរបស់កម្មវិធី PISA-D ឬ PISA។ ក្នុងកម្រិតនេះ សិស្សអាចស្វែងរកព័ត៌មាននៅក្នុងអត្ថបទអំណាន ឬតារាងស្ថិតិ ងាយយល់អំពីគំនិតគន្លឹះរបស់អត្ថបទដោយផ្អែកលើព័ត៌មានតិចតួចដែលបានផ្តល់ជូន (ពួកគេអាចធ្វើសេចក្តីសន្និដ្ឋានបាន) ធ្វើការប្រៀបធៀប និងឆ្លុះបញ្ចាំងទៅលើខ្លឹមសារអត្ថបទនៅក្នុងពិភពពិត។ ក្នុងករណីគណិតវិទ្យា សិស្សអាចយកទ្រឹស្តីទូទៅ ឬរូបមន្តគណិតវិទ្យាទៅអនុវត្ត ដោះស្រាយបញ្ហា ឬគណនាលេខនៅក្នុងការងារ ឬបរិបទស្ថានភាពនៃជីវិតពិត ដូចជាអត្រាប្តូរប្រាក់ ល្បឿន ឬចម្ងាយចរ និងពន្យល់ ឬបកស្រាយលទ្ធផលដែលរកឃើញជាដើម។ ចំពោះវិទ្យាសាស្ត្រ សិស្សអាចយកខ្លឹមសារ និងដំណើរការ ឬនិតិវិធីផ្សេងៗ ទៅអនុវត្ត ពន្យល់ ឬបកស្រាយទិន្នន័យ និងបាតុភូតផ្សេងៗនៅក្នុងធម្មជាតិ ឬស្ថានភាពជីវិតពិត ដូចជា កម្លាំងកកិត ទំនាញផែនដី និងអត្ថប្រយោជន៍លំហាត់សាច់ដុំ ឬសរសៃឈាមជាដើម។

ដោយប្រៀបធៀបជាមួយប្រទេសជាសមាជិក PISA-D ផ្សេងទៀត កម្រិតសមត្ថភាពរបស់សិស្សនៅក្នុងប្រទេសកម្ពុជាអាចនិយាយបានថា នៅកម្រិត “ទាប” ដែលក្នុងនោះសិស្សអាយុ១៥ឆ្នាំប្រហែលតែ ៨% ទៅ ១០% ប៉ុណ្ណោះទទួលបានសមត្ថភាពកម្រិតមូលដ្ឋាន (កម្រិតទី២) លើផ្នែកអំណាន និងគណិតវិទ្យា ខណៈដែលផ្នែកវិទ្យាសាស្ត្រ មានតែប្រមាណ ៥% ប៉ុណ្ណោះដែលឈានដល់កម្រិតសមត្ថភាពនេះ។ ដូចនេះសិស្សនៅកម្ពុជាមួយចំនួនតូចប៉ុណ្ណោះមានជំនាញមូលដ្ឋានសកល ដែលសម្រេចបានគោលដៅអប់រំក្នុងបរិបទ គោលដៅអប់រំប្រកបដោយចីរភាព (SDG4)។ កម្រិតសមត្ថភាពរបស់សិស្សអាចទាបជាងនេះ បើសិស្សអាយុ១៥ឆ្នាំដែលនៅស្ថិតនៅក្រៅសាលារៀនត្រូវបានបញ្ចូលនៅក្នុងសំណាក1 (MoEYS, 2018)។ ទោះជាយ៉ាងណាក៏ដោយ សិស្សទាំងនោះ អាចហៅថា “សិស្ស SDG” ដែលអាចប្រៀបធៀបបានសូម្បីតែជាមួយសិស្សមកពីបណ្តាប្រទេសដែលជាសមាជិក OECD។ ដើម្បីលុបបំបាត់គម្លាតលទ្ធផលសិក្សា កម្ពុជាត្រូវរៀនសូត្រពីលទ្ធផលសិក្សា ព្រមទាំងពីប្រព័ន្ធអប់រំរបស់គេយកជាចំណុចត្រូវរៀន និងជាផ្លូវទៅមុខទៀត ដើម្បីបង្កើនលទ្ធផលសិក្សារបស់សិស្សក្នុងដំណើរដ៏វែងឆ្ងាយ។

រូបភាពទី 2៖ ភាគរយសិស្សអាយុ១៥ឆ្នាំនៅកម្រិតសមត្ថភាពអប្បបរមា

[1] កម្រិតការសិក្សាទាបនេះត្រូវបានពិភាក្សាដោយ Michelle Kaffenberger, អ្នកស្រាវជ្រាវជាន់ខ្ពស់នៅក្នុងកម្មវិធី RISE តាមរយៈ: https://www.riseprogramme.org/blog/PISA-D_low_learning.




ប្រភព៖ ទិន្នន័យ PISA 2015 និង PISA-D

## *ការចូលរៀន និងបញ្ហាគុណភាព*

ទោះផ្អែកលើរង្វាស់ណាក៏ដោយ កម្ពុជានៅទាបជាងឆ្ងាយធៀបទៅនឹងកម្រិតសមត្ថភាពមូលដ្ឋានដែលបានកំណត់ជាសកល ដែលមានន័យថា កម្ពុជាត្រូវការគោលនយោបាយ និងសកម្មភាពឆ្លើយតបជាក់លាក់បន្ថែមទៀតដើម្បីដោះស្រាយវិបត្តិអប់រំបច្ចុប្បន្ន។ កំណែទម្រង់ដែលមានប្រសិទ្ធភាព និងរយៈពេលយូរអាចនឹងធ្វើឱ្យសិស្សអាយុ១៥ឆ្នាំ នៅកម្ពុជាទទួលបានលទ្ធផលល្អជាងនេះ យ៉ាងហោចណាស់ទទួលបានកម្រិតសមត្ថភាពទី២ ដោយសារសិស្សកម្ពុជាប្រហែល ៣៥% ស្ថិតក្នុងកម្រិតទី១ក (កម្រិតខ្ពស់បំផុតនៃកម្រិតទី១ និងជិតបំផុតទៅនឹងកម្រិតទី២) លើផ្នែកអំណាន និងប្រហែលជា៤២% នៅក្នុងកម្រិតទី១ក សម្រាប់ផ្នែកវិទ្យាសាស្ត្រ។ បន្ថែមពីលើនេះទៀត ដោយផ្អែកលើរង្វាស់ផ្សេងៗលទ្ធផល PISA-D បង្ហាញថា នៅក្នុងប្រទេសកម្ពុជាសិស្សគិតថា ការចូលរៀនគឺជា "សំណាងរបស់ពួកគេ" ដូចជាសិស្សមានអារម្មណ៍ថាខ្លួនគេជាចំណែកមួយរបស់សាលារៀន មានការពេញចិត្តនឹងជីវិតខ្ពស់ និងមានឥរិយាថវិជ្ជមានចំពោះសាលារៀន និងការសិក្សា ដែលនេះជាភាគលាភមួយសម្រាប់ការរីកចម្រើន និងអភិវឌ្ឍន៍ (MoEYS, 2018)។ តែទោះជាយ៉ាងណាក៏ដោយ "ការដែលសិស្សបានចូលរៀនគឺមិនដូចគ្នាទៅនឹងសិស្សបានរៀនសូត្រនោះទេ" (World Bank, 2018)។ ទោះបីការងារជាច្រើនកម្ពុជាបានធ្វើកន្លងមក តែទិន្នន័យ PISA-D បង្ហាញថា កម្ពុជាត្រូវដោះស្រាយបញ្ហាបន្ទាន់ជាច្រើននៅក្នុងកម្រិតសាលារៀន ជាពិសេសបញ្ហាសិស្សរៀនត្រួតថ្នាក់ អវត្តមាន ភាពយឺតយ៉ាវរបស់គ្រូ និងសិស្ស គុណភាពគ្រប់គ្រងសាលារៀនមិនល្អ ខ្វះវប្បធម៌ប្រឹងប្រែងរៀនសូត្រ និងការបែងចែកធនធានមិនស្មើភាពគ្នា រាប់

តាំងពីការបែងចែកគ្រូមិនស្មើគ្នាជាដើម។ កម្ពុជាក៏ត្រូវលុបបំបាត់គម្លាតនៃការអប់រំ និងអភិវឌ្ឍន៍គ្រូជាមួយនឹងប្រទេសសមាជិក PISA-D ASEAN និង OECD។ ទិន្នន័យ PISA-D បង្ហាញថា គុណវុឌ្ឍិគ្រូបង្រៀននៅកម្ពុជាគឺនៅមានកម្រិតទាបនៅឡើយ បើធៀបទៅនឹងប្រទេសសមាជិក PISA-D ASEAN និង OECD ផ្សេងទៀត ដែលក្នុងបណ្តាប្រទេសទាំងនោះ គ្រូបង្រៀននៅមធ្យមសិក្សាភាគច្រើនមានសញ្ញាបត្រយ៉ាងហោចណាស់ត្រឹមបរិញ្ញាបត្រ។

លទ្ធផលសិក្សាទាបរបស់សិស្សអាយុ១៥ឆ្នាំនៅក្នុងប្រទេសកម្ពុជា ក៏មានន័យដែរថា កម្ពុជាត្រូវការវិនិយោគបន្ថែមទៀតជាពិសេសទៅលើការអប់រំកុមារតូច និងបឋមសិក្សា និងគាំទ្រដល់សាលារៀនដែលខ្វះខាតបុគ្គលិក និងខ្វះខាតធនធាន ដែលជាទូទៅជាសាលារៀននៅតាមជនបទ។ ការធ្វើឱ្យមានតុល្យការថវិកាអប់រំឡើងវិញ ប្រហែលជាអាចជួយកាត់បន្ថយការចំណាយលើការអប់រំបន្ថែម(បំប៉ន) ឬការបោះបង់ការសិក្សារបស់សិស្សនៅថ្នាក់ខ្ពស់។ យោងលើទិន្នន័យ PISA-D ការវិនិយោគលើវិស័យអប់រំនៅក្នុងប្រទេសកម្ពុជានៅមានកម្រិតទាប (២.៧% នៃ ផ.ស.ស) នៅក្នុងតំបន់ និង PISA-D ដោយមិនទាន់គិតពីការជាក់ស្តែងមួយទៀតដោយភាគច្រើននៃថវិកាត្រូវចំណាយទៅលើប្រាក់ខែគ្រូបង្រៀន។ ជារួម កម្ពុជាត្រូវធ្វើដំណើរវែងឆ្ងាយដើម្បីធ្វើឱ្យមានមូលដ្ឋានគ្រឹះសម្រាប់ភាពជោគជ័យ នៅកម្រិតសាលារៀន (Willms, 2015)។ គោលនយោបាយ និងសកម្មភាពជាក់លាក់ដែលមានផលជះផ្ទាល់ដល់ការគ្រប់គ្រងសាលារៀន និងការសិក្សារបស់សិស្ស វាជាការឆ្លើយតបដ៏ត្រឹមត្រូវ និងរយៈពេលវែងមួយ។

## **ទិដ្ឋភាពអប់រំនៅក្នុងបរិបទ** PISA៖ **តើត្រូវទៅណា**?

កម្ពុជាបានធ្វើអ្វីជាច្រើនដើម្បីបង្កើនគុណភាពអប់រំ តាមរយៈកំណែទម្រង់ផ្សេងៗ ដោយពង្រឹងក្នុងចំណោមការងារផ្សេងទៀត ការប្រឡងថ្នាក់ទី១២ ការអប់រំគ្រូ ការដឹកនាំសាលារៀន កម្មវិធីសិក្សា ប្រព័ន្ធអធិការកិច្ចក៏ដូចជាការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សជាដើម។ ប៉ុន្តែអ្វីដែលចង់បានពីកំណែទម្រង់ទាំងនេះមិនទាន់បានសម្រេចចេញជារូបរាងពេញលេញនៅឡើយទេ។ ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិបង្ហាញដូចៗគ្នាថា លទ្ធផលសិក្សារបស់សិស្សនៅមានកម្រិតទាបនៅឡើយ (MoEYS, 2016; 2017; 2018)។ លទ្ធផលPISA-D បង្ហាញទៀតថា សិស្សអាយុ១៥ឆ្នាំរបស់កម្ពុជាភាគច្រើនខ្វះបំណិនមូលដ្ឋានលើផ្នែកអំណាន និងគណិតវិទ្យា ដែលចំណុចនេះរំលេចថា ការសិក្សារៀនសូត្រមិនបានកើតឡើងស្របតាមអ្វីដែលកំណត់នៅក្នុងកម្មវិធីសិក្សានៅមធ្យមសិក្សានៅឡើយទេ។ ប៉ុន្តែ ការពិតមួយដែល PISA ធ្វើការវាស់វែងសិស្សទៅលើអក្ខរកម្មសម្រាប់អនុវត្តក្នុងស្ថានភាពជាក់ស្តែងដែលសិស្សទទួលបានចាប់តាំងពីកម្រិតថ្នាក់ទាបមក (OECD, 2017) មានន័យថា កម្ពុជាត្រូវយកចិត្តទុកដាក់ទៅលើកម្មវិធីសិក្សា ការបង្រៀន និងរៀន និងការវាយតម្លៃ ដែលអនុវត្តក្នុងបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ។ ការដោះស្រាយបញ្ហានេះ ត្រូវការកំណែទម្រង់ប្រព័ន្ធអប់រំស៊ីជំរៅ និងមានសង្គតភាព ពីការអប់រំកម្រិតថ្នាក់ក្រោមមក (គួរតែសង្កត់ធ្ងន់លើអប់រំកម្រិតមូលដ្ឋាន)។

ជាការពិត ការចូលរួមរបស់ប្រទេសកម្ពុជានៅក្នុងកម្មវិធី PISA ២០២១ ឆ្លុះបញ្ចាំងពីការតាំងចិត្តខ្ពស់ក្នុងដំណើរឆ្ពោះទៅរកឧត្តមភាពនៅក្នុងប្រព័ន្ធអប់រំ។ ប៉ុន្តែផ្លូវឆ្ពោះទៅកាន់ការទទួលបានលទ្ធផលល្អនៅក្នុងកម្មវិធី PISA ត្រូវការកំណែទម្រង់មួយដ៏ស៊ីជំរៅ និងត្រឹមត្រូវ (OECD, 2013; Schleicher, 2018)។ នៅក្នុងបរិបទ PISA ការបង្រៀនឱ្យសិស្សមានចំណេះដឹង និង

ជំនាញសកល ក្នុងការទាញយកព័ត៌មាន វិភាគ និងវាយតម្លៃអត្ថបទខ្លីៗ មធ្យម និងវែងៗ ដោះស្រាយលំហាត់គណិតវិទ្យា និងបាតុភូតវិទ្យាសាស្រ្តផ្សេងៗ គឺជាអ្វីដែលល្អបំផុតសម្រាប់សិស្សដែលធ្វើតេស្ត PISA។ ទន្ទឹមនឹងនេះ សិស្សត្រូវតែអនុវត្តកិច្ចការ ឬលំហាត់ផ្សេងៗដែលមានលក្ខណៈច្រើនប្រភេទ ជាប្រចាំ ដើម្បីធ្វើឱ្យប្រសើរឡើងនូវបំណិននៃការគិតរបស់ពួកគេ (ស្របគ្នានឹងកម្រិតនៃការគិតរបស់លោកប្លូម) និងបណ្តុះវប្បធម៌អាន និងរៀនសូត្រដោយខ្លួនឯង។ ប៉ុន្តែ តើអ្វីទៅដែលយើងអាចធ្វើបាន និងត្រូវតែធ្វើសម្រាប់ការអប់រំនៅកម្ពុជាដើម្បីធ្វើឱ្យរឿងទាំងនេះកើតឡើងពិតប្រាកដ?

លទ្ធផល PISA-D សម្រាប់ប្រទេសកម្ពុជា និងប្រទេសជាសមាជិកផ្សេងទៀតហាក់ដូចជាបង្ហាញផ្លូវថា បែបបទអប់រំនាពេលកន្លងមកត្រូវការការពិនិត្យឡើងវិញ ហើយដូចគ្នាដែរគោលនយោបាយ និងការអនុវត្តនាពេលបច្ចុប្បន្ននៅមិនទាន់មានឥទ្ធិពលដោយផ្ទាល់លើការរៀនសូត្ររបស់សិស្សនៅឡើយទេ។ និយាយឱ្យចំ សកម្មភាពមួយចំនួន បើទោះជាមាន គឺមិនទាន់ដំណើរការប្រកបដោយប្រសិទ្ធភាពនៅក្នុងកម្រិតសាលារៀននៅឡើយទេ។ ប្រព័ន្ធអប់រំមួយត្រូវតែធានាថា សិស្សពិតជារៀនសូត្រពិតប្រាកដមែន នៅពេលដែលពួកគេបានចុះឈ្មោះចូលរៀនរួច។ ប្រព័ន្ធអប់រំដែលជោគជ័យ ដូចជាប្រទេសកូរ៉េ ប្រេស៊ីល អេស្តូនៀ និងសូម្បីតែវៀតណាម គឺជាប្រព័ន្ធដែលមានការតាំងចិត្តខ្ពស់ក្នុងការប្រើប្រាស់លទ្ធផលរបស់ PISA ដើម្បីកែលម្អការបង្រៀន និងរៀន ព្រមទាំងការវិនិយោគ និងការបែងចែកថវិកានៅក្នុងវិស័យអប់រំ។ ការបង្កើនការអប់រំរបស់គ្រូ និងការធានាឱ្យមានប្រព័ន្ធពិនិត្យតាមដាន និងគណនេយ្យភាពដ៏រឹងមាំមួយ គឺជាចំណុចគន្លឹះដែលនាំឱ្យប្រទេសទាំងនោះទទួលបានលទ្ធផលសិក្សា PISA ខ្ពស់។ ការធ្វើឱ្យមានភាពស្របគ្នានូវអ្វីដែលត្រូវធ្វើតេស្ត និងអ្វីដែលត្រូវបង្រៀននៅក្នុងថ្នាក់ គឺជាការអនុវត្តដែលចំចំណុចក្នុងចំណោមប្រទេសដែលជោគជ័យក្នុងកម្មវិធី PISA បើទោះជាមិនទាំងអស់ក៏ដោយ។ តាមរយៈនេះ កម្ពុជាត្រូវការរកឱ្យឃើញទាំងពីរនូវដំណោះស្រាយធ្វើលឿនបានផលលឿន និងដំណោះស្រាយរយៈពេលវែងសម្រាប់ការអប់រំបច្ចុប្បន្ន និងនាពេលអនាគត ដើម្បីបន្ស៊ីការអប់រំរបស់ខ្លួនទៅនឹងបរិបទសកលឱ្យកាន់តែប្រសើរឡើងដូចជា SDG ឬPISA ជាដើម។

## តើអ្វីខ្លះដែលអ្នកគោលនយោបាយគួរធ្វើ?

សង្ខេបគោលនយោបាយនេះ គឺមិនបានលម្អិតគ្រប់គ្រាន់ទេ តែបានរំលេចចេញនូវបញ្ហាគន្លឹះមួយចំនួនដែលអាចធ្វើបាន និងត្រូវតែធ្វើ ដើម្បីបង្កើនលទ្ធផលសិក្សារបស់សិស្ស ក៏ដូចជាបង្កើននូវមូលដ្ឋានគ្រឹះសម្រាប់ភាពជោគជ័យនៃការអប់រំនៅប្រទេសកម្ពុជា (Willms, 2015)។ ជម្រើសខាងក្រោមនេះគឺមានប្រយោជន៍សម្រាប់គិតអំពីគោលនយោបាយអប់រំ ការសិក្សាស្រាវជ្រាវ និងការអនុវត្តផ្សេងៗក្នុងកំណែទម្រង់អប់រំ៖

- បង្កើន និងប្រើប្រាស់ឱ្យបានទូលំទូលាយនូវការចំណាយរបស់រដ្ឋលើការអប់រំនៅក្នុងកម្រិតមត្តេយ្យសិក្សា និងបឋមសិក្សា ដើម្បីធានាថាសិស្សបានចូលរៀន និងជាពិសេសមានបំណិនក្នុងការគិតកម្រិតខ្ពស់ សម្រាប់អនុវត្តកិច្ចការអំណាន និងគណិតវិទ្យាដែលមានលក្ខណៈវែងៗ និងដែលត្រូវការការគិតកម្រិតខ្ពស់។ ក្នុងចំណុចនេះ សាលារៀន និងគ្រូបង្រៀនត្រូវពិនិត្យឡើងវិញ និងអភិវឌ្ឍកិច្ចការ ឬលំហាត់ផ្សេងៗ ដែលបង្កើនកម្រិតពុទ្ធិរបស់សិស្ស តាមកម្រិតនីមួយៗ និង

បញ្ចូលកិច្ចការ ឬលំហាត់ទាំងនោះនៅក្នុងការវាយតម្លៃកម្រិតថ្នាក់រៀន មិនថាជាការវាយតម្លៃតាមដំណាក់ ឬការវាយតម្លៃបញ្ចប់នោះទេ។

- អភិវឌ្ឍ ឬកែលម្អប្រព័ន្ធពិនិត្យតាមដាន និងប្រឹក្សាសាលារៀន ធៀបនឹងស្តង់ដាដែលបានកំណត់ ក្នុងគោលបំណងធ្វើឱ្យមានមូលដ្ឋានគ្រឹះសម្រាប់ភាពជោគជ័យនៅកម្រិតសាលារៀន។
- បន្តលើកកម្ពស់ការបណ្តុះបណ្តាលគ្រូបង្រៀន និងវិធីបង្រៀនផ្សេងៗ ឱ្យស្របគ្នាទៅនឹងក្របខណ្ឌសមត្ថភាពសកលដែលវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាត្រូវបានលើកកម្ពស់នៅក្នុងការបង្រៀន និងរៀន និងបន្តគាំទ្រដល់សាលារៀនដែលជួបការលំបាក។
- បណ្តុះបណ្តាល និងប្រើប្រាស់គ្រូបង្រៀនដែលលើស ដើម្បីផ្តល់ការបង្រៀនបន្ថែមដល់សិស្សដែលងាយរងគ្រោះ និងសិស្សខ្សោយ ដើម្បីកាត់បន្ថយអត្រារៀនត្រួតថ្នាក់។
- លើកតម្កើងការបង្រៀន និងរៀនដោយផ្អែកលើលទ្ធផលសិក្សា និងកញ្ចប់សមត្ថភាព នៅក្នុងបណ្តាមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូទាំងអស់ និងនៅកម្រិតសាលារៀន។
- បង្កើនឱកាសរៀននៅក្នុង និងក្រៅថ្នាក់រៀន ដោយបញ្ចូលបន្ថែមកិច្ចការរៀនសូត្រផ្សេងៗទៅក្នុងការបង្រៀន និងរៀន។ កិច្ចការនេះសុទ្ធតែអាចធ្វើបាន និងត្រូវតែធ្វើ ហើយវាមិនត្រូវការចំណាយច្រើននោះទេ។

## ឯកសារយោង


MoEYS. (2016). *Results of grade three student achievement from the national assessment in 2015.* Phnom Penh: MoEYS.

MoEYS. (2017). *Results of grade six student achievement from the national asssessment in 2016.* Phnom Penh: MoEYS.

MoEYS. (2018). *Education in Cambodia: Findings from Cambodia's experience in PISA for Development.* Phnom Penh: MoEYS.

MoEYS. (2018). *K-12 student learning assessment framework.* Phnom Penh: MoEYS.

MoEYS. (2018). *Results of grade 8 student achievement from the national asssessment in 2017.* Phnom Penh: MoEYS.

OECD. (2013). *PISA 2012 Results: What Makes Schools Successful? Resources, Policies and Practices (Volume IV).* OECD Publishing. doi:10.1787/9789264201156-en

OECD. (2016). *PISA 2015 Results (Volume I): Excellence and Equity in Education.* OECD Publishing. doi:10.1787/9789264266490-en

OECD. (2017). PISA 2015 Assessment and Analytical Framework: Science, Reading, Mathematic, Financial Literacy and Collaborative Problem Solving. In *PISA.* OECD Publishing, Paris. doi:http://dx.doi.org/10.1787/9789264281820-en

Schleicher, A. (2018). *World Class: How to build a 21st-century school system.* Paris: OECD Publishing.

UNESCO. (2015). *Student learning assessment.* Bangkok: UNESCO.

Willms, J. (2015). *Educational Prosperity.* Fredericton: The Learning Bar Inc.

World Bank. (2018). *Learning to realize education's promise.* Washington DC: World Bank.